វគ្គបណ្ដុះបណ្ដាលអាជីវកម្មថ្នាក់មូលដ្ឋានសម្រាប់
សហគ្រិនស្ត្រីមានពិការភាពប៉ែកជាយសមុទ្រ

Coastal Incubator Program for Women Entrepreneurs with Disabilities



# អាយុគ្រាន់តែជាតួរលេខ : ស្ត្រីមានពិការភាព ស្ត្រីមានពិការភាពក្នុងដំណើរឆ្ពោះទៅ សហគ្រិនភាពក្នុងវ័យ ៦៧ឆ្នាំ

## Age is Just a Number : Women with Disabilities on Her Way To Entrepreneurship at 67 years old


Author : SATHYA Hato
Edtior : CHY Socheata / MOM Ranna

# អាយុគ្រាន់តែជាតួរលេខ : ស្ត្រីមានពិការភាពក្នុងដំណើរឆ្ពោះទៅសហគ្រិនភាពក្នុងវ័យ ៦៧ឆ្នាំ

ស្ថិតក្នុងវ័យ ៦៧ឆ្នាំ **លោកស្រី ដួង លី** ជាសិក្ខាកាមស្ត្រីមានពិការភាពដៃខាងឆ្វេងដែលកំពុងតែមានគម្រោងពង្រីកអាជីវកម្មចិញ្ចឹមមាន់អោយកាន់តែប្រសើរដើម្បីកែប្រែជីវិតរបស់ខ្លួននៅក្នុងឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង។ ទោះបីជាលោកស្រីមានវ័យចំណាស់សុខភាពថមថយ និងពិការភាពដោយសារតែឧបទេវហេតុគ្រោះថ្នាក់ចរាចរណ៍ក៏ពិតមែនប៉ុន្តែលោកស្រីបានបង្ហាញពីការប្តេជ្ញាចិត្ត និងភាពអត់ធ្មត់មិនផ្លាស់ប្តូរហើយបានក្លាយជាបុគ្គលគំរូម្នាក់ដែលគួរអោយកោតសរសើរ។ តាមរយៈក្តីប្រាថ្នាចង់មានភាពរីកចម្រើន និងដើរតាមចំណង់ចំណូលចិត្តរបស់ខ្លួន លោកស្រីបានស្រាវជ្រាវយ៉ាងល្អិតល្អន់ពីបច្ចេកទេសផ្សេងៗនៃការចិញ្ចឹមមាន់ពីអ្នកជំនាញដែលមានបទពិសោធន៍ក៏ដូចជាសម្រេចចិត្តចូលរួមក្នុងកម្មវិធី «វគ្គបណ្តុះបណ្តាលអាជីវកម្មថ្នាក់មូលដ្ឋានសម្រាប់សហគ្រិនស្ត្រីមានពិការភាពប៉ែកជាយសមុទ្រ» ដើម្បីយល់ដឹងអោយកាន់តែច្បាស់អំពីរបៀបគ្រប់គ្រងអាជីវកម្មមួយនេះ។

> «សព្វថ្ងៃខ្ញុំនៅផ្ទះចិញ្ចឹមសត្វព្រោះយើងមានទ្រុង និងមានកន្លែងទីធ្លាទូលាយដែរ។ អាជីពហ្នឹងចំចិត្តខ្ញុំចង់ធ្វើ តែខ្ញុំមិនមានលុយកាក់គ្រប់គ្រាន់តែបើធ្វើបានជោគជ័យទៅមុខខ្ញុំអាចសង្ឃឹមថាមានលុយមានកាក់ចាយហ្នឹងគេ។»

ក្រៅពីការចិញ្ចឹមមាន់តាមធម្មជាតិក្នុងទ្រុងដែលមានទំហំគួរសមមួយធ្វើឡើងពីឈើប្រក់ស័ង្កសី និងស្បូវហ៊ុំព័ទ្ធដោយសំណាញ់ លោកស្រីក៏ធ្លាប់បានចិញ្ចឹមជ្រូកពីមុនដែរប៉ុន្តែដោយសារបញ្ហាសុខភាព និងបន្ទុកក្នុងការមើលថែទាំ លោកស្រីក៏បោះបង់ចោលការចិញ្ចឹមសត្វជ្រូករួចងាកមកផ្តោតទៅលើតែការចិញ្ចឹមសត្វមាន់ដើម្បីរកប្រាក់ចំណូលបន្ថែម។ លោកស្រីទទួលស្គាល់ថាដើម្បីអោយអាជីវកម្មនេះមាននិរន្តរភាព ចំណេះដឹងជាដំណោះស្រាយដ៏សំខាន់ដែលនឹងជួយអោយលោកស្រីផ្លាស់ប្តូរពីការចិញ្ចឹមមាន់តាមធម្មជាតិទៅជាលក្ខណៈបច្ចេកទេស ព្រមទាំងផ្លាស់ប្តូរពីការធ្វើទីផ្សារបែបប្រពៃណីទៅជាអាជីវកម្មខ្នាតតូចមួយដែលមានផែនការទីផ្សារច្បាស់លាស់។ លោកស្រីត្រូវការជំនួយបច្ចេកទេសបន្ថែមទៀតដូចជាការផ្តល់អាហារបច្ចេកទេសថែទាំពេលសត្វមានជំងឺប្រភេទថ្នាំសង្កូវនិងវិធីសាស្ត្រគ្រប់គ្រងជារួមដើម្បីបង្កើនប្រសិទ្ធភាពក៏ដូចជាផលិតភាពនៃប្រតិបត្តិការ។ តាមរយៈការគាំទ្រនេះ លោកស្រីរំពឹងថានឹងជួយអោយលោកស្រីទទួលបានទិន្នផលខ្ពស់ និងធានាបាននូវសុខុមាលភាពរបស់សត្វមាន់ផងដែរ។ អំឡុងពេលបណ្តុះបណ្តាលដែលទើបតែបញ្ចប់ថ្មីៗនេះលោកស្រីបានបង្ហាញពីភាពឆ្នើមរបស់ខ្លួនតាមរយៈការស្គាល់ពីចំណុចខ្លាំងចំណុចខ្សោយ និងតម្រូវការអាជីវកម្មរួមមានបច្ចេកទេសមើលថែទាំសត្វ និងទំហំថវិកាដើម្បីទិញសម្ភារៈបន្ថែមមួយចំនួនទៀត។ លោកស្រីអាចជជែកវែកញែក និងផ្តល់ព័ត៌មានទាក់ទងនឹងផែនការអាជីវកម្មប្រកបដោយភាពជឿជាក់ហើយលោកស្រីត្រូវការការហ្វឹកហាត់បន្ថែមតិចតួចបំផុតពីលោកគ្រូអ្នកគ្រូ។ សម្រាប់មេរៀនវិញ លោកស្រីយល់ថាសុទ្ធសឹងតែជាមេរៀនល្អៗ និងមិនអាចមើលរំលងមេរៀនណាមួយបានឡើយត្បិតលោកស្រីក៏មានការភ្លេចភ្លាំងច្រើនហើយត្រូវការមានអ្នកជួយរំលឹកនូវចំណុចសំខាន់ៗទាំងនោះ។




លោកស្រី ដួង លី នៅក្នុងវេទិកាស្តីពី «ធុរកិច្ចស្តីពីស្ត្រីមានពិការភាព» និងការបញ្ចប់វគ្គបណ្តុះបណ្តាល ខេត្តកោះកុង ថ្ងៃច័ន្ទ ទី២៦ ខែមិថុនា ឆ្នាំ២០២៣

> «ខ្ញុំចាប់អារម្មណ៍ត្រង់មេរៀនចំណូលចំណាយជាងគេដើម្បីតាមដានខ្លួនឯងថារកចូល ហើយចាយវាយយ៉ាងម៉េច។ ខ្ញុំក៏បានអនុវត្តការកត់ត្រាចំណូលចំណាយហើយឃើញថា ប្លែកព្រោះយើងរកឃើញកន្លែងដែលយើងចូល និងកន្លែងដែលយើងចាយ។»

ចំណេះដឹង និងភាពជឿជាក់ដែលលោកស្រីទទួលបាននៅក្នុងវគ្គបណ្តុះបណ្តាលបានជំរុញអោយលោកស្រីមានគម្រោងពង្រីកអាជីវកម្មរបស់ខ្លួនដោយធ្វើទ្រុងមាន់ព្រមទាំងស្វែងរកពូជមាន់ល្អៗយកមកចិញ្ចឹមបន្ថែមទៀត។ លោកស្រីប៉ាន់ស្មានថាការពង្រីកអាជីវកម្មចិញ្ចឹមមាន់នេះនឹងទទួលបានជោគជ័យក្នុងរយៈពេល៦ខែខាងមុខប្រសិនបើលោកស្រីមានការគាំទ្របំពេញនូវរាល់កង្វះខាតទាំងនេះ។ ដោយមើលឃើញពីគុណតម្លៃនៃចំណេះដឹង លោកស្រីក៏សូមផ្តាំផ្ញើទៅកាន់ជនមានពិការភាពដទៃទៀតអោយព្យាយាមពង្រឹងសមត្ថភាពរបស់ខ្លួនតាមរយៈការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានា។

> «ខ្ញុំសូមអោយបងប្អូនមានពិការភាពទាំងអស់តាំងចិត្តតាំងស្មារតី ធ្វើកិច្ចការដែលយើងបានរៀនជាមួយលោកគ្រូអ្នកគ្រូ ហើយកុំបោះបង់ចោលអោយសោះ។ មិនងាយរកលោកគ្រូអ្នកគ្រូមកបង្រៀនអោយយើងមានចំណេះដឹងនោះទេ ហ្នឹងហើយជាលាភសក្ការៈសុខៗមានចំណេះចេះដឹង។ ដូចខ្ញុំអញ្ចឹង អាជីពហ្នឹងខ្ញុំចូលចិត្តណាស់តែខ្ញុំមិនដឹងទៅខាងណាអោយបានជោគជ័យតលូវបានគ្រូបង្រៀន ខ្ញុំដឹងច្បាស់ថាការងារខ្ញុំនឹងមានសង្ឃឹមទៅថ្ងៃមុខ។»

# Age is Just a Number : Women with Disabilities on Her Way To Entrepreneurship at 67 years old

At the age of 67 years old, **Mrs. DOUNG Ly** is a participant with left-hand impairment who currently plans to expand her chicken raising business to improve her life in Dong Peng commune, Sre Ambel district, Koh Kong province. Although she is an elderly with declining health and an impairment due to an accident, she has shown unwavering determination and patience and has become an admirable role model. With her desire to grow and follow her passions, she thoroughly researched various techniques in raising chickens from professionals and decided to participate in the "Coastal Incubator Program for Women Entrepreneurs with Disabilities" in order to acquire better understanding on how to manage her business.

> **"I am currently raising chickens at home because we have coops and a large yard. I want to pursue this career, but I do not have enough money. If I succeed, I hope to earn some money."**

Aside from traditionally raising chickens in reasonably sized coops made of corrugated iron sheets and thatched netting, she also used to raise pigs as well. However due to health conditions and workload, she gave up raising pigs and turned to focusing only on chickens as the main income source. She recognizes knowledge as the key to a sustainable business that will help her transition from family chicken raising to a technical practice, as well as shift from traditional marketing to a commercialized-small business with a well-prepared plan. In fact, she needs additional technical assistance on feeding, disease control methods, type of medicines and overall management procedure to increase efficiency and productivity. Through this support, she wishes to achieve greater results and ensure the well-being of the chickens. During the workshop, she demonstrated an outstanding performance through identifying her strengths, weaknesses and business needs which includes animal care techniques and budgeting to purchase additional equipment. She could openly discuss and provide information related to the business plan with confidence and she only required minimal facilitation from the facilitators and mentors. As for the lessons, she acknowledged the importance of every module that cannot be overlooked as she is a forgetful person and needs accommodation to help remind those key points.

> **"I am most interested in the income and expenditure lesson as it teaches us to keep track of how much we earn and spend. I also practiced recording my personal income and expenses and found it fascinating because I awared of when I earned and spent."**




Mrs. DOUNG Ly in "Women Entrepreneurs with Disabilities" Forum and Graudation Koh Kong, 26th June 2023

The knowledge and confidence that she gained in the workshop prompted her to plan in expanding her business by enlarging the chicken coops and sourcing for better breeds. She expects that her chicken raising business expansion will be successful in the next six months if she has all the support to fill in these gaps. Recognizing the value of knowledge, she would like to encourage other people with disabilities to strengthen their capacity by participating in various training programs if possible.

> **"I urge all person(s) with disabilities to concentrate on what we have learned with the teachers and do not give up. It is not easy to seek education from any teachers, this is the reward of happiness and knowledge. Just like me, I really like this career, but I do not know how to successfully achieve the goal. Now that I have knowledge from the facilitators and mentors, I am sure that my career will prosper in the future."**

«វគ្គបណ្តុះបណ្តាលអាជីវកម្មថ្នាក់មូលដ្ឋានសម្រាប់សហគ្រិនស្រ្តីមានពិការភាពប៉ែកជាយសមុទ្រ» ត្រូវបានបង្កើតឡើង និង អនុវត្តដោយសហគ្រាសសង្គម អ៊ែជ្យាយល៍ (Agile Development Group) សហការជាមួយអង្គការ អេដ អេ អាកស្យុង (AEA) តាមរយៈជំនួយឧបត្ថម្ភពី សហភាពអឺរ៉ុប ក្រោមគម្រោង «សមាជិកនៃសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED)» ក្នុងគោលបំណងអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជារស់នៅក្នុងសហគមន៍ក្បែរឆ្នេរសមុទ្រដែលពឹងផ្អែកលើការនេសាទជាប្រភពចំណូលចម្បង។

គម្រោងមួយនេះត្រូវបានអនុវត្តចាប់ពីខែមករា ដល់ខែ កក្កដា ឆ្នាំ២០២៣ផ្តោតសំខាន់ទៅលើការជួយដល់សហគ្រិនស្រ្តីដែលមានពិការភាព ក្នុងការកសាងអាជីវកម្មតាំងពីដំណាក់កាលដំបូង និង/ឬអាជីវកម្មដែលគ្រប់គ្រងដោយសហគ្រិនស្រ្តីដែលមានពិការភាពដែលនៅតែស្ថិតក្នុងដំណាក់កាលជាគំនិតអាជីវកម្មនៅឡើយ។

“Coastal Incubator Program for Women Entrepreneurs with Disabilities” is initiated and co-implemented by Agile Development Group and Aide Et Action Cambodia (AEA) co-funded by European Union in Cambodia under the project of “The Consortium for Sustainable Alternatives and Voice for Equitable Development (CO-SAVED)” in the purpose of improving the socio-economic development of Cambodians living in coastal communities who rely on fishing as their primary source of income.

This program is implemented from January to July 2023 to help women entrepreneurs with disabilities (WEDs) to build businesses from the ground up and/or businesses owned by WEDs that are still in their idea stage.